**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ ៤៩១ សហវ.ប្រក

# ប្រកាស

## ស្តីពី

## ការអនុវត្តន៍កម្មវិធីលុបបំបាត់ពន្ធនាំចូល និង របាំងមិនមែនពន្ធលើពាណិជ្ជកម្មក្នុងអាស៊ាន សម្រាប់ចំណែកទី ៣ នៃបញ្ជីផលិតផលបច្ចេកវិទ្យាព័ត៌មាន និង គមនាគមន៍ (ICT)

..................

## ឧបនាយករដ្ឋមន្ត្រី

## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៤ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការចាត់តាំងសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ជានាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ០៦ អនក្រ.បក ចុះថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ ២០០៣ ស្តីពីការបង្កើតនាយកដ្ឋានហិរញ្ញវត្ថុមូលដ្ឋាននៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

- បានឃើញអនុក្រឹត្យលេខ ៧៨ អនក្រ.បក ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០០៤ និង អនុក្រឹត្យលេខ ២០ អនក្រ.បក ចុះថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ២០០៨ ស្ដីពីការបំពេញបន្ថែម និង កែសម្រួលនាយកដ្ឋានមួយចំនួននៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៣៤ អនក្រ.បក ចុះថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្ដីពីការតម្លើងទីចាត់ការគយ និង រដ្ឋាករ នាយកដ្ឋានពន្ធដារ និងរតនាគារជាតិនៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ឱ្យទៅជាអគ្គនាយកដ្ឋានគយ និង រដ្ឋាករកម្ពុជា អគ្គនាយកដ្ឋានពន្ធដារ និងអគ្គនាយកដ្ឋានរតនាគារជាតិ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញភាពចាំបាច់ក្នុងការបំពេញកាតព្វកិច្ចដែលមានចែងនៅក្នុងកិច្ចព្រមព្រៀងក្របខ័ណ្ឌ អ៊ី-អាស៊ាន (e-ASEAN) ដែលបានចុះហត្ថលេខា នៅថ្ងៃទី ២៤ ខែ វិច្ឆិកា ឆ្នាំ ២០០០
- បានឃើញលិខិតលេខ ៤៦០៥ សហវ ចុះថ្ងៃទី ១០ ខែ កញ្ញា ឆ្នាំ ២០០២ របស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ស្ដីពីការសុំសេចក្ដីសម្រេចលើបញ្ជីផលិតផលបច្ចេកវិទ្យាព័ត៌មាន និង គមនាគមន៍ (ICT) និង កម្មវិធីលុបបំបាត់ពន្ធនាំចូល និងរបាំងមិនមែនពន្ធលើពាណិជ្ជកម្មក្នុងអាស៊ានសម្រាប់ចំណែកទី ៣ នៃបញ្ជី ICT និងការសម្រេចរបស់សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ជានាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## សម្រេច

**ប្រការ ១ :** ប្រកាសឱ្យអនុវត្តកម្មវិធីលុបបំបាត់ពន្ធនាំចូល និង របាំងមិនមែនពន្ធលើពាណិជ្ជកម្មក្នុងអាស៊ានសម្រាប់ចំណែកទី ៣ នៃបញ្ជីផលិតផលបច្ចេកវិទ្យាព័ត៌មាន និង គមនាគមន៍ (ICT) ។

**ប្រការ ២ :** ប្រកាសនេះ ចាប់មានប្រសិទ្ធិភាពអនុវត្ត ពីថ្ងៃទី ០១ ខែ មករា ឆ្នាំ ២០១០ តទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែមិថុនា ឆ្នាំ ២០០៩

**គាត ឈន់**

ចម្លងជូន:
- ទីស្ដីការគណៈរដ្ឋមន្ត្រី
- គ្រប់ក្រសួងស្ថាប័ន ខេត្ត ក្រុង
  "ដើម្បីជូនជ្រាប"
- អគ្គនាយកដ្ឋានគយ និង រដ្ឋាករកម្ពុជា
- អគ្គនាយកដ្ឋានពន្ធដារ
- នាយកដ្ឋានសមាហរណកម្មសេដ្ឋកិច្ច និងអាស៊ាន
  "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ